

# គម្ពីរសំយុត្តនិកាយ

(មានបិដក អដ្ឋកថា ដីកា ពន្យល់)

## ភិក្ខុនីសំយុត្ត

### បិដកខ្មែរភាគ ៣០

រៀបរៀង និងប្រែដោយ ភិក្ខុ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# សេចក្ដីផ្ដើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្ដីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្ដីសុខ សេចក្ដីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្ដីសុខ សេចក្ដីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២៣

ភិក្ខុសារត្ថធម្មោ នួន សារ៉េត

## ៥.ភិក្ខុនីសំយុត្តំ (បិដក)

## ១.អាឡវិកាសុត្តំ

(១)ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ។ អថ ខោ អាឡវិកា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តា យេន អន្ធវនំ តេនុបសង្កមិ វិវេកត្ថិនី។ អថ ខោ មារោ បាបិមា អាឡវិកាយ ភិក្ខុនិយា ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ វិវេកម្ហា ចាវេតុកាមោ យេន អាឡវិកា ភិក្ខុនី តេនុបសង្កមិ។ ឧបសង្កមិត្វា អាឡវិកំ ភិក្ខុនឹ គាថាយ អជ្ឈភាសិ៖

“នត្ថិ និស្សរណំ លោកេ កឹ វិវេកេន កាហសិ,
ភុញ្ជស្សុ កាមរតិយោ មាហុ បច្ឆានុតាបិនី”តិ។

អថ ខោ អាឡវិកាយ ភិក្ខុនិយា ឯតទហោសិ “កោ នុ ខ្វាយំ មនុស្សោ វា អមនុស្សោ វា គាថំ ភាសតី”តិ? អថ ខោ អាឡវិកាយ ភិក្ខុនិយា

ឯតទវោច “មារោ ខោ អយំ បាបិមា មម ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ វិវេកម្ហា ចាវេតុកាមោ គាថំ ភាសតី”តិ។ អថ ខោ អាឡវិកា ភិក្ខុនី “មារោ អយំ បាបិមា” ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ បច្ចភាសិ

“អត្ថិ និស្សរណំ លោកេ បញ្ញាយ មេ សុផុស្សិតំ
បមត្តពន្ធុ បាបិម ន ត្វំ ជានាសិ តំ បទំ ។
“សត្តិសូលូបមា កាមា ខន្ធាសំ អធិកុដ្ដនា
យំ ត្វំ កាមរតឹ ព្រូសិ អរតិ មយ្ហ សា អហូ”តិ ។

អថ ខោ មារោ បាបិមា “ជានាតិ មំ អាឡវិកា ភិក្ខុនី”តិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ។

## អាឡវិកាសូត្រ ទី១ (បិដក)

(១) ខ្ញុំបានស្តាប់មក យ៉ាងនេះ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ

ភិក្ខុនីឈ្មោះអាឡវិកា ស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហ-សម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងបច្ឆាភត្ត ក៏មានសេចក្តីត្រូវការ ដោយទីស្ងាត់ ហើយចូលទៅកាន់អន្ធវ័ន។

(២) គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាឡវិកាភិក្ខុនី មានប្រាថ្នាឲ្យនាងឃ្លាតចាកសេចក្តីស្ងប់ស្ងាត់ ហើយក៏ចូលទៅរកអាឡវិកាភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងអាឡវិកាភិក្ខុនីថា ធម្មជាតជាគ្រឿងរលាស់ចេញ [ព្រះនិព្វាន។] ក្នុងលោក មិនមានទេ នាងនឹងធ្វើនូវប្រយោជន៍អ្វីដោយសេចក្តីស្ងប់ស្ងាត់ ចូរនាងបរិភោគ នូវសេចក្តីត្រេកអរក្នុងកាម នាងពុំមានសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ។

(៣) គ្រានោះ អាឡវិកាភិក្ខុនី មានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលនូវគាថា។ ទើបអាឡវិកាភិក្ខុនី

មានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើង ដល់អាត្មាអញ ប្រាថ្នាឲ្យអាត្មាអញ ឃ្លាតចាកសេចក្តីស្ងប់ស្ងាត់ បានជាពោលនូវគាថា។ លុះអាឡវិកាភិក្ខុនី ស្គាល់ច្បាស់ថា នេះជាមារ មានចិត្តបាប ដូច្នេះហើយ ក៏ពោលគាថាទាំងឡាយ នឹងមារមានចិត្តបាបថា ធម្មជាត ជាគ្រឿងរលាស់ចេញក្នុងលោក មាន យើងបានពាល់ត្រូវដោយបញ្ញា [បច្ចវេក្ខណញ្ញាណ។] ម្នាលមារមានចិត្តបាប មានផៅពង្សជាអ្នកប្រមាទ អ្នកមិនដឹងនូវបទនោះទេ កាមទាំងឡាយ ឧបមាដោយលំពែងស្រួច ខន្ធទាំងឡាយជាកន្ឡែងសម្រាប់មុត នៃកាមទាំងឡាយនោះ អ្នកពោលនូវសេចក្តីត្រេកអរ ក្នុងកាមណា សេចក្តីត្រេកអរ ក្នុងកាមនោះ ជាសេចក្តីមិនត្រេកអរ របស់យើងទេ។

លំដាប់នោះ មារមានចិត្តបាបដឹងថា អាឡវិកាភិក្ខុនី ស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ។

# ៥.ភិក្ខុនីសំយុត្តំ

## ១.អាឡវិកាសុត្តវណ្ណនា (អដ្ឋកថា)

(១)ភិក្ខុនីសំយុត្តស្ស បឋមេ អាឡវិកាតិ អាឡវិយំ ជាតា អាឡវិនគរ-តោយេវ ច និក្ខម្ម បព្វជិតា។ អន្ធវនន្តិ កស្សបសម្មាសម្ពុទ្ធស្ស ចេតិយេ នវកម្មត្ថាយ ធនំ សមាទបេត្វា អាគច្ឆន្តស្ស យសោធរស្ស នាម ធម្មភាណក-ស្ស អរិយបុគ្គលស្ស អក្ខីនិ ឧប្បាដេត្វា តត្ថេវ អក្ខិភេទប្បត្តេហិ បញ្ចហិ ចោរសតេហិ និវុត្ថត្តា តតោ បដ្ឋាយ “អន្ធវន”ន្តិ សង្ខំ គតំ វនំ។ តំ កិរ សាវត្ថិតោ ទក្ខិណបស្សេ គាវុតមត្តេ ហោតិ រាជារក្ខាយ គុត្តំ។ តត្ថ បវិវេកកាមា ភិក្ខូ ច ភិក្ខុនិយោ ច គច្ឆន្តិ។ តស្មា អយម្បិ កាយវិវេកត្ថិនី យេន តំ វនំ, តេនុបសង្កមិ។ និស្សរណន្តិ និព្វានំ។ បញ្ញាយាតិ បច្ចវេក្ខណ-ញាណេន។ ន ត្វំ ជានាសិ តំ បទន្តិ ត្វំ ឯតំ និព្វានបទំ វា និព្វានគាមិមគ្គ-បទំ វា ន ជានាសិ ។ សត្តិសូលូបមាតិ វិនិវិជ្ឈនត្ថេន សត្តិសូលសទិសា ។ ខន្ធាសំ អធិកុដ្ដនាតិ ខន្ធា តេសំ អធិកុដ្ដនភណ្ឌិកា។ បឋមំ។

# អ ដ្ឋ ក ថា

## អាឡវិកាសូត្រទី ១

ក្នុងភិក្ខុនីសំយុត្ត ***អាឡវិកាសូត្រទី*** ១ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១] *បទថា* ***អាឡវិកា*** *សេចក្តីថា អ្នកកើតក្នុងក្រុងអាឡវី និងចេញបួសពីក្រុងអាឡវីនុ៎ះឯង ។ បទថា* ***អន្ធវនំ*** *សេចក្តីថា ព្រៃដែលឈ្មោះថា អន្ធវ័ន តាំងពីវេលាដែលពួកចោរ ៥០០ នាក់ ខ្វេះភ្នែកទាំងពីររបស់ព្រះអរិយបុគ្គល (អនាគាមី) អ្នកពោលធម៌ នាមថា* ***យសោធរ*** *ជាអ្នករួបរួមទ្រព្យមកដើម្បីសាងព្រះចេតិយព្រះសម្មាសម្ពុទ្ធព្រះនាមថា* ***កស្សប*** *ខ្លួនឯងក៏បែកភ្នែកនៅក្នុងទីនោះឯង ។ គេដំណាលមកថា ព្រៃនោះ ជាព្រៃរក្សានូវពួកម្រឹគ ក្នុងផ្ទៃដីប្រមាណមួយគាវុតផ្នែកទិសទក្សិណក្រុងសាវត្ថី បុគ្គលដែលត្រូវការវិវេក និងភិក្ខុនីទាំងឡាយ ក៏នាំគ្នាទៅក្នុងព្រៃនោះ ។ ព្រោះដូច្នោះ សូម្បីភិក្ខុនីអាឡវិកានេះ ក៏មានសេចក្តីត្រូវការវិវេក ទើបចូលទៅកាន់ព្រៃនោះ ។*

[៣] *បទថា* ***និស្សរណំ*** *បានដល់ ព្រះនិព្វាន ។ បទថា* ***បញ្ញាយ***

បានដល់ បច្ចវេក្ខណញ្ញាណ ។ បទថា **ន ត្វំ ជានាសិ តំ បទំ** សេចក្តីថា អ្នកមិនដឹងបទ គឺ ព្រះនិព្វាន ឬបទ គឺ មគ្គ ដែលទៅកាន់ព្រះនិព្វាន ។ បទថា **សត្តិសូលូបមា** បានដល់ ដូចជាលំពែង និងដែកស្រួច ព្រោះអត្ថថា ជាគ្រឿងចាក់ដោត ។ បទថា **ខន្ធាសំ អធិកុដ្ដនា** សេចក្តីថា គំនរនៃកាមទាំងឡាយនោះ ដូចជាបូស ។

ចប់អដ្ឋកថា អាឡវិកាសូត្រទី ១

# ៥.ភិក្ខុនីសំយុត្តំ (ភិក្ខុនីសំយុត្ត)

## ១.អាឡវិកាសុត្តវណ្ណនា (ដីកា)

(១)អាឡវិយំ ជាតាតិ អាឡវិយំ វិជាយិត្វា សំវឌ្ឍមានា។ តេនាហ “អាឡវិនគរតោយេវ ច និក្ខម្ម បព្ពជិតា”តិ។ ធនំ សមាទបេត្វាតិ ចេតិយស្ស រាជា ឯកំ មុខំ, រាជបុត្តោ ឯកំ, អមច្ចានំ ជេដ្ឋកោ ហុត្វា សេនាបតិ ឯកំ, ជនបទានំ ជេដ្ឋកោ ហុត្វា សេដ្ឋិ ឯកន្តិ ឯវំ ចតូសុ មុខេសុ នវកម្មេ កយិរមានេ សេដ្ឋិនា គហិតមុខេ កម្មេ ឱលីយមានេ ឯកោ ឧបាសកោ អរិយសាវកោ បញ្ច សកដសតានិ យោជាបេត្វា ជនបទំ គន្ត្វា “យោ យំ ទាតុំ ឧស្សហតិ ហិរញ្ញំ វា សុវណ្ណំ វា សត្តវិធរតនំ វា ហរិតាលំ វា មនោសិលំ វា, សោ ធនំ ទេតូ”តិ សមាទបេត្វា យថាលទ្ធំ បឋមំ កម្មដ្ឋានំ បេសេត្វា “នវកម្មំ និដ្ឋិត”ន្តិ សុត្វា ឯកកំ អាគច្ឆន្តំ អន្តរាមគ្គេ ចោរា បលិពុន្ធិត្វា តតោ កិញ្ចិ ធនំ អលភន្តា “សចេ នំ មុញ្ចិស្សាម, អនត្ថំ នោ ករេយ្យា”តិ ជីវិតា វោរោបេសុំ។ អនបរាធេ អរិយសាវកេ អបរាធកា តេ ចោរា អន្ធា ជាតា, តស្មា តំ ឋានំ

“អន្ធវន”ន្តិ បញ្ញាយិត្វាតិ អដ្ឋកថាយំ វុត្តំ។ ខីណាសវានំ យស្មា យត្ថ កត្ថចិ ចិត្តវិវេកោ ហោតិយេវ ឧបធិវិវេកស្ស សិទ្ធត្តា។ តស្មា “កាយវិវេកត្ថិនី”តិ វុត្តំ។

និស្សរណន្តិ និព្វានំ សព្វសង្ខតស្ស និស្សដត្តា។ បច្ចវេក្ខណញាណេនាតិ បច្ចវេក្ខណញាណេន, បគេវ មគ្គផលញាណេហីតិ អធិប្បាយោ។ និព្វានបទន្តិ និព្វានសង្ខាតំ ធម្មកោដ្ឋាសំ។ វិនិវិជ្ឈនដ្ឋេនាតិ ហទយំ វិនិវិទ្ធេន ហទយម្ហិ វិជ្ឈិត្វា ទុក្ខុប្បាទនេន ខន្ធានំ ឯតេ បញ្ច កាមា សត្តិសូលសទិសា។ អធិកុដ្ដនភណ្ឌិកាតិ អាឃាតនយដិកា។

អាឡវិកាសុត្តវណ្ណនា និដ្ឋិតា។

(១) ពីរបទថា កើតហើយក្នុងដែនអាឡវី មានសេចក្តីថា ប្រសូតចម្រើនឡើងហើយក្នុងដែនអាឡវី ។ ព្រោះហេតុនោះ បានជាលោកអាចារ្យពោលថា បព្វជិតទាំងឡាយរមែងចាកចេញអំពីដែនអាឡវី ។ កាលដែលគេធ្វើនវកម្មបួន

មុខ កម្មគឺលោកសេដ្ឋីមានគ្រហស្ថជាប្រធានអន់ថយ មានឧបាសកជាអរិយសាវ័កមួយនាក់ ទឹមដោយរទេះ ៥០០ ហើយបរទៅកាន់ជនបទដោយគិតយ៉ាងនេះថា ព្រះរាជាបានថ្វាយវត្ថុមួយមុខចំពោះព្រះចេតិយ បានជាព្រះរាជបុត្រមួយអង្គ, សេនាបតីមួយនាក់ បានជាច្បងនៃអាមាត្យទាំងឡាយ, លោកសេដ្ឋីមួយនាក់ បានជាច្បងនៃអ្នកជនបទទាំងឡាយ ។ ហើយញ៉ាំងគេឲ្យកាន់យកនូវកម្មដ្ឋាន ហើយបញ្ជូននូវកម្មដ្ឋានជាដំបូងតាមសមគួរ ដោយបំណងថា បុគ្គលណាព្យាយាមឲ្យនូវវត្ថុណា ទោះបីជា មាសក្តី ប្រាក់ក្តី រតនៈប្រាំពីរប្រការក្តី ហរិតាល (វត្ថុមួយប្រភេទស្មើរជាថ្មតែទន់សម្បុរលឿងខ្ចី)ក្តី ថ្មមនោសិលា (ម្នាងសិលា)ក្តី បុគ្គលនោះ ចូរឲ្យនូវទ្រព្យចុះ។ តពីនោះមកពួកចោរទាំងឡាយកាលមកតាមផ្លូវ បានស្តាប់ឮថា នវកម្មសម្រេចហើយ បានដេញតាមក្រោយ (នៃសេដ្ឋីនោះ) កាលមិនបាននូវទ្រព្យ បានគិតថា អញនឹងញ៉ាំងសេដ្ឋីចាកជីវិត ប្រសិនបើអញនឹងធ្វើនូវសេដ្ឋីនោះចាកជីវិត ពួកយើងឈ្មោះថា គប្បីធ្វើកម្មមិនជាប្រយោជន៍ ។ ពួកចោរទាំងឡាយនោះ ជាអ្នកមានទោសក្នុងគុណព្រះអរិយបុគ្គលដោយពិត ព្រោះជាបុគ្គលល្ងីតល្ងង់ ។

ព្រោះហេតុនោះ ទើបអដ្ឋកថាពោលប្រាកដថា ព្រែងងឹត ។ បុគ្គលជាព្រះខីណាស្រពពួកខ្លះ ជាចិត្តវិវេកតែម៉្យាង ព្រោះភាវៈនៃឧបធិវិវេក ។ ព្រោះហេតុនោះ ទើបលោកពោលថា កាយវិវេក ។ បទថា នូវការអាស្រ័យ មានសេចក្ដីថា ព្រោះភាវៈនៃការអាស្រ័យនូវព្រះនិព្វានជាបច្ច័យតាក់តែងទាំងពួង ។ បទថា បច្ចវេក្ខណញ្ញាណ មានសេចក្ដីថា ដោយការពិចារណា ។ អធិប្បាយថា ពុំចាំបាច់ពោលថ្វីដោយមគ្គញ្ញាណ និង ផលញ្ញាណ ។ បទថា និព្វានបទ មានសេចក្ដីថា ចំណែកនៃធម៌ ពោលគឺព្រះនិព្វាន ។ បទថា ដោយការជ្រាបច្បាស់ មានសេចក្ដីថាកាមគុណប្រាំនៃខន្ធទាំងឡាយនោះ ដោយការកើតឡើងនៃទុក្ខ ហើយជ្រាបច្បាស់ក្នុងហ្ឫទ័យ ព្រោះការជ្រាបច្បាស់ក្នុងហ្ឫទ័យ ឈ្មោះថា ប្រាកដស្មើដោយចុងនៃដែកស្រួច។ ការចងអាឃាត ឈ្មោះថា អធិកុដ្ដនភណ្ឌិក ។

អាឡវិកាភិក្ខុនីសូត្រ ចប់

បើមានការខុសត្រង់កន្លែងណាមួយ សូមលោកអ្នកចេះដឹងទាំងឡាយជួយកែតម្រូវផង!

សូមអរគុណ!